# ៤. ធ្វើឱ្យឱកាសអប់រំមានសំរាប់ទាំងអស់គ្នា

**ការហាមឃាត់មិនឲ្យមានការរើសអើង**

អនុសញ្ញាស្តីពីសិទ្ធិកុមារនៅក្នុងក្របខ័ណ្ឌសកម្មភាពក្រុងដាកាបានសង្កត់ធ្ងន់លើកាតព្វកិច្ចរបស់រដ្ឋាភិបាលទាំងអស់ក្នុងការធានាផ្តល់ការអប់រំសំរាប់កុមារគ្រប់រូប ជាបុគ្គលក្តី ជាសមូហភាពក្តីដើម្បីលុបបំបាត់ ការបែងចែក ឬការរើសអើង។ ការបដិសេធន៍ជាស្ថាប័ន ឬតាមច្បាប់មិនឲ្យមានឱកាសចូលរៀនត្រូវបានដាក់ឲ្យនៅក្រៅច្បាប់សកលលោករួចជាស្រេចហើយ។ ក្របខ័ណ្ឌសកម្មភាពក្រុងដាកាបានផ្តល់លទ្ធភាពនិងឱកាសចូលរៀនដល់កុមារដែលត្រូវគេទាត់ចោលកុមាររងគ្រោះ និងទន់ខ្សោយ។

និយមន័យនៃពាក្យនេះមានន័យខុសគ្នាច្រើនណាស់។ ឧទាហរណ៍ ស្នងការហ្វីលីពីនទទួលបន្ទុកសិទ្ធិមនុស្សបានកំណត់និមយន័យរបស់ពាក្យ "ជនទន់ខ្សោយ" ថាជា "ស្រ្តី កុមារ យុវជន ពិរុទ្ធជន អ្នកក្រីក្រតាមទីប្រជុំជន ជនជាតិដើម ចាស់ជរា ជនជាតិអ៊ីស្លាម ជនពិការ ជនមានជំងឺសរសៃប្រសាទ មនុស្សធ្វើការក្នុងពលកម្មក្រៅផ្លូវការ មនុស្សធ្វើការក្នុងពលកម្មឯកជន កម្មករភៀសខ្លួន កម្មករនៅទីជនបទ និងនៅក្នុងផ្នែករដ្ឋការផងដែរ"។[២០] បន្ថែមទៅលើក្របខ័ណ្ឌសកម្មភាពក្រុងដាកា កំណត់អាទិភាពគ្រប់យុទ្ធសាស្រ្តរួមបញ្ចូលទាំងអស់របស់អប់រំ :

"ការប្រឈមមុខសំខាន់គឺធានាថា ចក្ខុវិស័យទូលំទូលាយនៃការអប់រំសំរាប់ទាំងអស់គ្នាក្នុងលក្ខណ:រួមបញ្ចូលត្រូវបានឆ្លុះបញ្ចាំងឲ្យឃើញនៅក្នុងគោលនយោបាយរបស់រដ្ឋាភិបាល និងរបស់ភ្នាក់ងារផ្តល់ជំនួយហិរញ្ញវត្ថុ។ ការអប់រំសំរាប់ទាំងអស់គ្នាត្រូវតែគិតគូរដល់អ្នកក្រីក្រ និងអ្នកដែលទន់ខ្សោយ និងប្រជាជនជួបការលំបាកបំផុត ដោយរួមបញ្ចូលទាំងកុមារពលកម្ម អ្នករស់នៅតំបន់ដាច់ស្រយាល និងអ្នកគ្មានទីលំនៅជនជាតិភាគតិច កុមារ និងយុវជនដែលទទួលរងគ្រោះដោយសារសង្គ្រាម និងជំងឺអេដស៍ ជនអត់ឃ្លាន និងមនុស្សដែលមានសុខភាពទន់ខ្សោយ និងអ្នកដែលមានតម្រូវការសិក្សាពិសេស"។[២១]

កុមារដែលត្រូវគេបដិសេធមិនឲ្យចូលរៀនមានលក្ខណ:ខុសគ្នាពីប្រទេសមួយទៅប្រទេសមួយទៀត ឬពី តំបន់មួយទៅតំបន់មួយទៀតនៅក្នុងប្រទេសតែមួយ។ ប៉ុន្តែគួរឲ្យសោកស្តាយណាស់ ដែលទិន្នន័យប្រៀបធៀបមានតិចតួចប៉ុណ្ណោះនៅក្នុងព័ត៌មានស្ថិតិអប់រំនៅក្នុងការវាយតម្លៃការអប់រំសំរាប់ទាំងអស់គ្នា។ ការធ្វើរបាយការណ៍ក្នុងសន្ធិសញ្ញាសិទ្ធិមនុស្ស ជាពិសេសអនុសញ្ញាស្តីពីសិទ្ធិកុមារព្យាយាមបង្ហាញអំពីកុមារដែលត្រូវ គេបដិសេធមិនឲ្យមានឱកាសចូលរៀន។

ប្រទេសកម្ពុជាបានសង្កត់ធ្ងន់ថា *"នៅតំបន់ដាច់ស្រយាល ឬតំបន់គ្មានសុវត្ថិភាពស្ទើរតែពុំមានការចុះបញ្ជីកំណើតទាល់តែសោះ ដោយហេតុថា ឪពុកម្តាយមិនយកចិត្តទុកដាក់ ឬគ្មានមធ្យោបាយ។ នៅទីក្រុងការចូលរៀនកើនដល់ ៩៥ ភាគរយ។ ចំណែកនៅតំបន់ដាច់ស្រយាល ឬព្រៃភ្នំ ការចូលរៀនបានតែ ៤០ ភាគរយប៉ុណ្ណោះ។ ចំណែកកូនជនជាតិភាគតិចវិញ ការចូលរៀនបានតែ ៥ ភាគរយប៉ុណ្ណោះ។ លើសពីនេះទៀត កម្ពុជាបានកត់ត្រាកុមារដែលមិនបានចូលរៀនជាកុមារកំព្រា កុមារដែលត្រូវឪពុកម្តាយបោះបង់ចោល កុមាររបស់គ្រួសារក្រីក្រ ក្មេងអនាថារស់នៅតាមទីសាធារណ: អ្នកបំរើ ពិរុទ្ធកុមារ ឬ យុវវ័យដែលមានអាយុពី ៧ ទៅ ១៧ ឆ្នាំ កុមារពិការ កុមាររកស៊ីកផ្លូវភេទ អ្នកសុំទាន និងអ្នករើសអេបចាយ។*[២២]

---

[20] Commission on Human Rights - 12 Years of Human Rights Advocacy: 1998 Annual Report , Quezon City, p. 7.

[21] The Dakar Framework for Action - Education for All: Meeting Our Collective Commitments, Expanded Commentary , para. 19.

[22] Initial report of Cambodia under the Convention on the Rights of the Child, CRC/C/11/Add.16, 1998.

ប្រហាក់ប្រហែលគ្នានេះដែរ "នៅប្រទេសវៀតណាម នៅតំបន់ព្រៃភ្នំ ជនបទដាច់ស្រយាលមានកុមារជាច្រើនមានអាយុពី ៦ ទៅ ១៤ ឆ្នាំ ដែលមិនបានចុះឈ្មោះចូលរៀន បោះបង់ការសិក្សា ឬរៀនត្រួតថ្នាក់ ជាពិសេស ក្មេងស្រីដោយហេតុផលផ្សេងគ្នាជាច្រើន ដូចជា កង្វះសាលា ឬបន្ទប់រៀន ចម្ងាយពីផ្ទះទៅសាលាឆ្ងាយ។ បញ្ញត្តិច្បាប់ស្តីពីការចុះបញ្ជីកំណើតមិនទាន់អនុវត្តឲ្យបានហ្មត់ចត់នៅឡើយនៅតំបន់ជាច្រើន ជាពិសេសនៅតំបន់ព្រៃភ្នំ និងជនបទដាច់ស្រយាល។ កុមារមួយចំនួនធំមិនទាន់មានសំបុត្រកំណើត ឬសំបុត្រស្នាក់នៅ។ កង្វះឯកសារនេះធ្វើឲ្យកុមារមានការលំបាកក្នុងការចុះឈ្មោះចូលរៀន"។[២៣]

ប្រទេសថៃបានរៀបរាប់ពីការមិនបានចូលរៀនរបស់ក្មេងមួយចំនួនថា "មានកុមារមួយចំនួនត្រូវបានជួញដូរពីប្រទេសជិតខាង។ ច្បាប់ប្រទេសថៃចាត់ទុកកុមារទាំងនេះជាជនភៀសខ្លួនខុសច្បាប់។ គួរឲ្យសោកស្តាយណាស់ដែលថា កុមារទាំងនេះមិនអាចទទួលបានសិទ្ធិដូចសិទ្ធិដែលកុមារថៃទូទៅបានទទួល។ កុមារទាំងនេះមិនបានចូលរៀនទេ ហើយត្រូវបានគេចាប់បង្ខំឲ្យធ្វើជាស្រីពេស្យា ឬអ្នកបំរើតាមផ្ទះ។ អ្នកដែលទទួលការរំលោភបំពាន ទាំងលើរាងកាយ និងផ្លូវចិត្ត ដូចជា ការដាក់ទណ្ឌកម្ម ការកេងប្រវ័ញ្ច និងបង្ខំឲ្យធ្វើជាស្រីពេស្យាមិនទទួលបានសេវាសង្គមកិច្ច និងផលប្រយោជន៏ផ្សេងទៀតដែលពួកគេគួរទទួលនោះទេ។ កុមារដែលមានសភាពប្រហាក់ប្រហែលគ្នានេះដែរគឺជាកូនគ្រួសារក្រីក្រ កូនកម្មករសំណង់ កូនជនជាតិភាគតិច។ កុមារពិការកម្រទទួលបានការស្តារលទ្ធភាព និងសមត្ថភាពឡើងវិញណាស់។ កុមារដែលមានមេរោគអេដស៏ ឬជំងឺអេដស៏កំពុងតែកើនឡើង ហើយកុមារទាំងនេះនឹងបង្កបញ្ហាជាច្រើនដល់សង្គមជាតិទៅថ្ងៃអនគត។ កុមារភាគច្រើនដែលមិនបានទទួលការសិក្សាស្ថិតនៅតំបន់ជនបទដាច់ស្រយាល កូនគ្រួសារក្រីក្រ កុមាររស់នៅក្នុងតំបន់សំណង់អនាធិបតេយ្យ កុមារដែលមានភាសា និងវប្បធម៏ខុសគ្នា កុមាររបស់ជនជាតិភាគតិច និងកុមាររស់នៅតាមកោះ"។[២៤]

ភាពដូចគ្នា និងភាពខុសគ្នាក្នុងការពណ៌នាខាងលើនេះបញ្ជាក់ថា ឧបសគ្គក្នុងការប្រយុទ្ធប្រឆាំងនឹងការមិនបានចូលរៀនរបស់កុមារខុសគ្នាជាច្រើន ប៉ុន្តែកត្តាទាំងអស់កំណត់ដោយភាពក្រីក្រ។ សំរាប់កុមារជនជាតិហេតុផលដែលមិនបានរៀនអាចរួមបញ្ចូលទាំងភាសាយានក្នុងការបង្រៀននៅក្នុងសាលា។ ចំណែកកូនរបស់គ្រួសារជនភៀសខ្លួន អាចបណ្តាលមកពីឧបសគ្គផ្សេងទៀត ដូចជាច្បាប់ ឬរដ្ឋបាលដែលសិទ្ធិទទួលការអប់រំត្រូវបានកំណត់ថាសំរាប់តែពលរដ្ឋស្របច្បាប់។

### ៤.១. ការហាមឃាត់ជាសកលស្តីពីការរើសអើង

តារាងទី ៨ មានមូលដ្ឋានដែលគេហាមឃាត់ជាសកលមិនឲ្យមានការរើសអើង។ ក្នុងរយៈពេល ៥០ ឆ្នាំកន្លងមកនេះ ការហាមឃាត់លើការរើសអើងត្រូវបានពង្រីកឲ្យកាន់តែច្រើនពីពីរ ឬបីចំណុច (សញ្ជាតិ ពណ៌សម្បុរ ភេទ សាសនា ឬទស្សនៈនយោបាយ) ឲ្យកាន់តែច្រើន ដែលសំខាន់សំរាប់កុមារ ដូចជា (ការរើសអើងប្រឆាំងនឹងកុមារដែលកើតពីឪពុកម្តាយដែលមិនបានរៀបការត្រឹមត្រូវ) និងឪពុកម្តាយពិការ។ ដំណើរការដាក់ឲ្យនៅក្រៅច្បាប់នៃការរើសអើងទាំងនេះកំពុងតែដំណើរការ តែក៏នៅមានចំណុចមួយចំនួនពុំទាន់ត្រូវបានដាក់ឲ្យនៅក្រៅច្បាប់ជាសកលនៅឡើងដែរ។ ឧទាហរណ៍ ទោះបីជាការរើសអើងប្រឆាំងនឹងជនជាតិ ដែលមិនមែនជាជនជាតិដើមរបស់ប្រទេសគួរលុបចោល ដោយអនុលោមទៅតាមអនុសញ្ញាស្តីពីសិទ្ធិកុមារដែលទាមទារ

23 Second periodic report of Viet Nam under the Convention on the Rights of the Child, 2000.

24 Initial report of Thailand under the Convention on the Rights of the Child, U.N. Doc. CRC/C/11/Add.13, paras. 50, 69-70, and 342.

ឲ្យមានសិទ្ធិអប់រំសំរាប់កុមារគ្រប់រូបនៅក្នុងប្រទេសនីមួយៗ ច្បាប់ជាតិតែងមានលក្ខណ:តឹងរឹងក្នុងការកំណត់អ្នកដែលមានសិទ្ធិទទួលការអប់រំ។ ទម្រង់ថ្មីនៃការរើសអើង ដូចជាការឆ្លងមេរោគអេដស៍ ដែលបានចាប់ផ្តើមឆ្លងរាលដាលកាលពីពីរទសវត្សរ៍កន្លងមកកំពុងលុបបាត់តាមផ្លូវច្បាប់។

នៅពេលដែលការហាមឃាត់ជាលក្ខណ:អន្តរជាតិប្រឆាំងនឹងការរើសអើងហាក់ដូចជាត្រូវបានរំលឹកឡើងវិញនៅក្នុងប្រព័ន្ធផ្លូវច្បាប់ជាច្រើន ការងារលុបបំបាត់ការរើសអើងជាក់ស្តែងកំពុងតែប្រឈមមុខនឹងរដ្ឋាភិបាលជាច្រើននៅក្នុងពិភពលោក។ ការដាក់ឲ្យនៅក្រៅច្បាប់នៃការបដិសេធន៍សិទ្ធិទទួលការអប់រំចំពោះកុមារ (កុមារី កុមារជនជាតិភាគតិច កុមារពិការ) គឺជាជំហានដំបូងដើម្បីបញ្ជាក់ឡើងវិញពីការធ្វើសកលកម្មនៃសិទ្ធិទទួលការអប់រំដើម្បីឆ្លើយតបនឹងកាតព្វកិច្ចនៃការពង្រីកការអប់រំសំរាប់កុមារទាំងអស់។ ដំណាក់កាលដំបូង — ការហាមឃាត់ជាផ្លូវការប្រឆាំងនឹងការមានឱកាសមិនស្មើគ្នា — ត្រូវតែរួមជាមួយនឹងការខិតខំប្រឹងប្រែងដើម្បីដោះស្រាយបញ្ហារើសអើងដែលមានជាច្រើនឆ្នាំមកហើយ។

**តារាង ៨ : កាហាមឃាត់ជាសកលស្តីពីការរើសអើង**

| | UN Bill of Rights[a] | CRC[b] | CoE[c] | OAS[d] | OAU[e] |
|---|---|---|---|---|---|
| សញ្ជាតិ | មាន | មាន | មាន | មាន | មាន |
| ភេទ | មាន | មាន | មាន | មាន | មាន |
| ភាសា | មាន | មាន | មាន | មាន | មាន |
| សាសនា | មាន | មាន | មាន | មាន | មាន |
| គំនិត | មាន | មាន | មាន | មាន | មាន |
| ប្រទេសកំណើត | មាន | មាន | មាន | មាន | មាន |
| ទ្រព្យសម្បត្តិ | មាន | មាន | មាន | មាន | មាន |
| ស្ថានភាពសេដ្ឋកិច្ច | មាន | មាន | មាន | មាន | មាន |
| កំណើត | មាន | មាន | មាន | មាន | មាន |
| ឋាន:សង្គម | មាន | មាន | មាន | មាន | មាន |
| ជនជាតិភាគតិច | មិនមាន | មិនមាន | មាន | មិនមាន | មាន |
| ពិការភាព | មិនមាន | មាន | មិនមាន | មិនមាន | មិនមាន |

a. ***អង្គការសហប្រជាជាតិ :*** *ច្បាប់អន្តរជាតិស្តីពីសិទ្ធិមនុស្សមានសេចក្តីប្រកាសសកលនៃសទ្ធិមនុស្ស (១៩៤៨) និង កតិកាសញ្ញាស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងសិទ្ធិវប្បធម៌ និងសិទ្ធិពលរដ្ឋ និងនយោបាយ (១៩៦៦)*

b. ***អនុសញ្ញាស្តីពីសិទ្ធិកុមារ*** *បានហាមឃាត់មូលហេតុនៃការរើសអើងផ្សេងទៀត ជាពិសេសការរើសអើងចំពោះកុមារពិការ*

c. ***ក្រុមប្រឹក្សាអឺរ៉ុប :*** *អនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (១៩៥០) កត់ត្រា និងកំណត់សិទ្ធិពលរដ្ឋ និងនយោបាយ និងការហាមឃាត់ប្រឆាំងនឹងការរើសអើងត្រូវបានគេដាក់អោយអនុវត្តនៅឆ្នាំ ២០០០ តាមរយ:កិច្ចព្រមព្រៀងលេខ ១២។ ច្បាប់សង្គមកិច្ចរបស់អឺរ៉ុប (អនុម័តនៅឆ្នាំ ១៩៦១ និងធ្វើវិសោធនកម្មនៅឆ្នាំ ១៩៩៦)ទាក់ទងនឹងសិទ្ធិសង្គម និងសេដ្ឋកិច្ច។*

d. ***អង្គការរដ្ឋអាមេរិក :*** *អនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្សទាក់ទងនឹងសិទ្ធិនយោបាយ និងពលរដ្ឋ។ កិច្ចព្រមព្រៀងនៃ San Salvador ទាក់ទងនឹងសិទ្ធិសេដ្ឋកិច្ច និងសង្គម។*

e. ***អង្គការសហព័ន្ធអាហ្វ្រិក :*** *ច្បាប់អាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងសិទ្ធិពលរដ្ឋទាក់ទងនឹងសិទ្ធិសង្គមកិច្ច សេដ្ឋកិច្ច នយោបាយ សិទ្ធិពលរដ្ឋ សិទ្ធិបុគ្គល និងសិទ្ធិសហគមន៍*

អនុសញ្ញាស្តីពីសិទ្ធិកុមារមានកំណត់អំពីការហាមឃាត់យ៉ាងទូលំទូលាយទាក់ទងនឹងការរើសអើង ដូចដែលមានបង្ហាញនៅក្នុងតារាងទី ៨។ អនុសញ្ញានេះមានក្របខ័ណ្ឌវិភាគស៊ីជំរៅ ដែលនៅក្នុងក្របខ័ណ្ឌនេះ គេអាចវិភាគអំពីភាពដូចគ្នា និងភាពខុសគ្នានៅតាមប្រទេសនីមួយៗ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏មានរូបភាពផ្សេងទៀតដែលកុមារអាចនឹងទទួលការរើសអើង ដូចជាក្នុងករណីដែលកុមារនៅក្រៅអាយុដែលបានកំណត់តាមច្បាប់ជាដើម។ ការចូលរៀនត្រូវកំណត់តាមអាយុមួយច្បាស់លាស់ ហើយអ្នកដែលនៅក្មេងពេក ឬចាស់ពេកអាចទទួលបានការបដិសេធន៍មិនឲ្យចូលរៀន។

### ៤.២. ដំណើរការនៃការលុបបំបាត់ការរើសអើង

ទម្រង់នៃការរើសអើងមានការប្រែប្រួលទៅតាមពេលវេលា និងភូមិសាស្ត្រ។ យុទ្ធសាស្ត្ររបស់រដ្ឋាភិបាលដើម្បីលុបបំបាត់ការរើសអើងមានវិធានការច្បាប់អប់រំ និងហិរញ្ញប្បទានទៅតាមប្រភេទនៃការវិនិយោគដែលចាំបាច់។ ការធានាមិនឲ្យមានការប្រកាន់ពូជសាសន៏ ការប្រកាន់កុមារពិការទាមទារឲ្យមានការបង្កើនធនធានហិរញ្ញប្បទាន។ ការធានាគុណភាពសំរាប់កុមារីទាមទារឲ្យមានការអប់រំសាធារណៈដែលមាននិរន្តរភាព និងការកែទម្រង់ផ្លូវច្បាប់ដើម្បីធ្វើឲ្យកុមារី និងស្ត្រីទទួលបានសិទ្ធិពេញលេញក្នុងការអប់រំ។

ការរីកចំរើនឆ្ពោះទៅសំរេចសមភាពក្នុងការចូលរៀនអាចបង្ហាញតាមរយៈការប្រមើលមើលកត្តាពីរដែលកំពុងតែមានការកើនឡើងស្របពេលគ្នា : ទីមួយគឺការរីកដុះដាលជាបន្តបន្ទាប់នៃសិទ្ធិទទួលការអប់រំ និង ទីពីរការបញ្ចូលជាបន្តបន្ទាប់នូវអ្នកដែលគេមិនបានបញ្ចូលពីមុនទៅក្នុងប្រព័ន្ធអប់រំ។ អាទិភាពដែលគេបានភ្ជាប់ទៅក្នុងការអប់រំបឋមសិក្សានៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ រួមផ្សំជាមួយនឹងផែនការសំរេចការអប់រំសំរាប់ទាំងអស់គ្នានៅមុន ឬត្រឹមឆ្នាំ ២០១៥ បង្ហាញពីការឯកភាពគ្នាជាសកលលើបញ្ហានេះ។ ការរីកចំរើននៃការទទួលស្គាល់សិទ្ធិទទួលអប់រំក៏មាននៅក្នុងការបង្កើនពេលវេលានៅក្នុងការអប់រំដោយកាតព្វកិច្ច និងការធានាឲ្យមាន ការអប់រំថ្នាក់ក្រោមដោយកាតព្វកិច្ចផងដែរ។

ព័ត៌មានស្ថិតិដែលវាយតម្លៃការរីកចំរើននៅក្នុងការប្រយុទ្ធប្រឆាំងនឹងការរើសអើងនៅក្នុងការអប់រំដោយប្រើការហាមឃាត់ជាលក្ខណៈអន្តរជាតិធ្វើជាខ្នាតវាស់វែងនៅមានតិចតួចណាស់។ លើសពីនេះទៀតព័ត៌មានទាំងនោះត្រូវបានរៀបចំឡើងនៅក្នុងប្រភេទតែមួយប៉ុណ្ណោះ ជាពិសេស ទាក់ទងនឹងយេនឌ័រ សញ្ជាតិ ឬពិការភាពនៅពេលដែលការរើសអើងក្នុងទម្រង់ផ្សេងទៀតមិនទាន់ឃើញមានសម្បុរបែប។ ប្រវត្តិសាស្ត្របង្ហាញប្រាប់យើងថា សមាជិកក្រុមដែលត្រូវបានគេទាត់ចេញពីការអប់រំគឺជាក្រុមទទួលបានអាទិភាពតិចតួចបំផុតក្នុងការអប់រំ។ ច្បាប់សិទ្ធិមនុស្សអន្តរជាតិសង្កត់ធ្ងន់ មិនត្រឹមតែលើការហាមឃាត់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងការលុបបំបាត់ដោយសកម្មនៃការរើសអើង ជាពិសេស ការរើសអើងប្រឆាំងនឹងកុមារី និង ស្ត្រី។

ការងារនេះមានលក្ខណៈកាន់តែស្មុគស្មាញ ពីព្រោះថា ការរើសអើងគឺជាបាតុភាពដែលត្រូវបានប្រមែប្រមូលទុកជាយូរយារមកហើយ។ ឧទាហរណ៏ ប្រទេសថៃបានកត់សំគាល់ថា "ការអប់រំនៅតែជាវិស័យមួយដ៏សំខាន់ដែលស្ត្រី និងកុមារីពិការជួបការលំបាកខ្លាំងខាងការរើសអើងជាងបុរស និងកុមារា"។[២៥] លើសនេះទៀត កង្វះការអប់រំជាមូលហេតុធ្វើឲ្យមានភាពឯកកោដែលប្រជាជននៅក្នុងស្ថានភាពបែបនេះអាចជាជនជាតិដើម ឬជនជាតិភាគតិច។ ការអប់រំអាចទាមទារឲ្យពួកគេទទួលយកភាសា សាសនា ឬទំនៀមទំលាប់នៃជីវិតមួយផ្សេងទៀត។

បញ្ញត្តិស្តីពីការមិនរើសអើងនៅក្នុងការអប់រំមានបញ្ចូលនៅក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិសំខាន់ៗ ដូចដែលបង្ហាញនៅក្នុងតារាងទី ៩។ បញ្ញត្តិនេះរួមបញ្ចូលទាំងកាតព្វកិច្ចជាក់លាក់របស់រដ្ឋាភិបាលក្នុងការហាមឃាត់មិនឲ្យមានការរើសអើងនៅក្នុងឱកាសនៃការចូលរៀន រហូតដល់កាតព្វកិច្ចដែលនឹងត្រូវបំពេញនៅក្នុងពេលយូរអង្វែងដែលទាក់ទងនឹងការរើសអើងនៅក្នុងការអប់រំតាមរយៈការកែប្រែកម្មវិធីសិក្សា និង

25 Second and third periodic reports under the Convention on the Elimination of All Forms of Discrimination against Women, U.N. Doc. CEDAW/C/THA/2-3, 1997, para. 28.

សៀវភៅសិក្សា ដែលកម្មវិធីសិក្សា និងសៀវភៅសិក្សាទាំងនេះអាចបង្ហាញពីការមិនស្មើភាពគ្នាក្នុងរូបភាពមួយចំនួនដូចជា ស្ត្រី ជនជាតិភាគតិច ជនពិការ ឬជនជាតិដើម។

**បញ្ញត្តិស្តីពីគ្មានការរើសអើងក្នុងការអប់រំ**

## តារាងទី ៩ : បញ្ញត្តិគន្លឹះស្តីពីការមិនរើសអើងក្នុងការអប់រំ

***អនុសញ្ញាយូណេស្កូប្រឆាំងនឹងការរើសអើងក្នុងការអប់រំ (១៩៦០)***

*ភាគីរដ្ឋនៅក្នុងអនុសញ្ញានេះត្រូវបង្កើត និងអនុវត្តគោលនយោបាយជាតិដែល នឹងព្យាយាមជំរុញឲ្យមានសមភាព កាលានុប្បវត្ត និងទង្វើនានា*

*...ពាក្យ "រើសអើង" រួមបញ្ចូលការបែងចែក ការកំហិត ឬការពេញចិត្តដែលផ្អែកលើសញ្ជាតិ ពណ៌សម្បុរ ភេទ ភាសា សាសនា នយោបាយ មតិយោបល់ ជាតិ ឬសញ្ជាតិកំណើត ស្ថានភាពសេដ្ឋកិច្ច ឬកំណើត មានគោលបំណងធ្វើឲ្យប៉ះពាល់ដល់សមភាពនៃទង្វើនៅក្នុងការអប់រំ និងជាពិសេស :*

*(ក) រារាំងបុគ្គលណាម្នាក់ ឬក្រុមណាមួយមិនឲ្យចូលរៀននៅក្នុងការអប់រំប្រភេទណាមួយ ឬកំរិតណាមួយ*

*(ខ) កំហិតបុគ្គលណាម្នាក់ ឬក្រុមណាមួយឲ្យទទួលការអប់រំដែលមានស្តង់ដាទាបជាង*

*(គ) ... បង្កើត ឬរក្សាប្រព័ន្ធអប់រំ ឬស្ថាប័នអប់រំដាច់ដោយឡែក ... (ប្រព័ន្ធបែបនេះអាចអនុញ្ញាតឲ្យមានសំរាប់សិស្សទាំងពីរភេទ ដោយហេតុផលសាសនា ឬភាសា ហើយសាលាឯកជន ក៏អនុញ្ញាតឲ្យមានដែរ បើគោលបំណងសាលាបែបនោះមិនទាត់ចោល ក្រុមណាមួយ)។*

***អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់ការរើសអើង ការប្រកាន់ពូជសាសន៍គ្រប់ទម្រង់ (១៩៦៥)***

*ភាគីរដ្ឋត្រូវហាមឃាត់ និងលុបបំបាត់ការរើសអើងប្រកាន់ពូជសាសន៍គ្រប់ទម្រង់ និងត្រូវធានាសិទ្ធិពលរដ្ឋគ្រប់រូបដោយគ្មានការបែងចែក ដូចជា សញ្ជាតិ ពណ៌សម្បុរ ជាតិ ឬជនជាតិភាគតិច ដោយស្មើភាពគ្នា នៅចំពោះមុខច្បាប់ ជាពិសេសចំពោះការទទួល បានសិទ្ធិ ...*

*(v) សិទ្ធិទទួលការអប់រំ និងការបណ្តុះបណ្តាល*

*ភាគីរដ្ឋត្រូវអនុម័តវិធានការមានប្រសិទ្ធភាព និងបន្ទាន់ ជាពិសេសនៅក្នុងការបង្រៀន និងការអប់រំ វប្បធម៌ និងព័ត៌មានដោយមានគោលការណ៍ប្រឆាំងនឹងការប្រកាន់ពូជសាសន៍។*

***សន្ធិសញ្ញាស្តីពីការលុបបំបាត់ការរើសអើងគ្រប់ទម្រង់ប្រឆាំងនឹងស្ត្រី (១៩៧៩)***

*ភាគីរដ្ឋនឹងចាត់វិធានការសមស្របដើម្បីលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីដើម្បីធានាឲ្យស្ត្រីមានសិទ្ធិស្មើគ្នាដូចបុរសនៅក្នុងវិស័យអប់រំ និង ជាពិសេសដើម្បីធានាលើមូលដ្ឋានស្មើភាពគ្នារវាងបុរស និងស្ត្រី :*

*(ខ) មានឱកាសរៀនកម្មវិធីដូចគ្នា ការប្រលងដូចគ្នា គ្រូបង្រៀនដែលមានកំរិតវប្បធម៌មានស្តង់ដាដូចគ្នា និងទីធ្លាសាលា និងសម្ភារសិក្សាមានគុណភាពដូចគ្នា*

*(គ) លុបបំបាត់រាល់ទស្សនៈបែងចែកតួនាទីបុរស ស្ត្រី នៅគ្រប់កំរិត និងគ្រប់ទម្រង់នៃការសិក្សា ដោយការសិក្សាជាមួយគ្នា*

*(ង) ការកាត់បន្ថយអត្រាបោះបង់ចោលការសិក្សារបស់សិស្សស្រី និងការរៀបចំកម្មវិធីសិក្សាសំរាប់កុមារី និង ស្ត្រីដែលបោះបង់ការសិក្សាមុនពេលពួកគេមានការចេះដឹង។*

*(ច) ទទួលព័ត៌មានអប់រំជាក់លាក់ដើម្បីថែទាំងសុខភាព និងសុខុមាលភាពគ្រួសារ រួមបញ្ចូលទាំងព័ត៌មាន និងដំបូន្មានទាក់ទងនឹងការធ្វើផែនការគ្រួសារ។*

***អនុសញ្ញាអង្គការពលកម្មពិភពលោកស្តីពីជនជាតិដើម និងជនជាតិភាគតិច (១៩៨៩)***

*វិធានការនឹងត្រូវចាត់តាំងដើម្បីធានាថា សមាជិកជនជាតិដើមមានឱកាសទទួលការអប់រំនៅគ្រប់កំរិតយ៉ាងហោចណាស់ក៏ក្នុងលក្ខណៈស្មើភាពគ្នាជា មួយនឹងប្រជាជននៅក្នុងសហគមន៍ជាតិដែរ។*

*កម្មវិធី និងសេវាអប់រំសំរាប់ជនជាតិដើមនឹងត្រូវរៀបចំ និងអនុវត្តដោយមានការសហការជាមួយជនជាតិដើម ដើម្បីដោះស្រាយបញ្ហាពិសេសរបស់ជនជាតិដើម និងរួមបញ្ចូលប្រវត្តិសាស្ត្ររបស់ជនជាតិដើម ចំណេះដឹង និង បច្ចេកវិទ្យារបស់ជនជាតិដើម និងប្រព័ន្ធគុណធម៌ និងផ្នែកផ្សេងៗទៀតដែលទាក់ទងនឹងវប្បធម៌ សេដ្ឋកិច្ច និងសង្គមរបស់ជនជាតិដើមទៅថ្ងៃក្រោយ។*

*ការផ្សព្វផ្សាយចំណេះដឹង និងជំនាញទូទៅដែលជួយកុមារជនជាតិដើមឲ្យចូលរួមដោយពេញលេញ និង ដោយស្មើភាពនៅក្នុងសហគមន៍នឹងក្លាយជាគោលបំណងនៃការអប់រំសំរាប់ជនជាតិដើម។*

*វិធានការអប់រំនឹងត្រូវបានចាត់តាំងឡើងក្នុងចំណោមផ្នែកផ្សេងៗទៀតនៃសហគមន៍ជាតិ និងជាពិសេសក្នុងចំណោមផ្នែកទាំងឡាយដែលទាក់ទងដោយផ្ទាល់ជាមួយជនជាតិដើម ដោយមានគោលបំណង លុបបំបាត់ការប្រកាន់ពូជសាសន៍។ ក្នុងន័យនេះ ការខិតខំប្រឹងប្រែងនឹងត្រូវធ្វើឡើងដើម្បីធានាថា សៀវភៅប្រវត្តិសាស្ត្រ និងឯកសារអប់រំផ្សេងទៀតផ្តល់ព័ត៌មានត្រឹមត្រូវ និងស្មើភាពរបស់សង្គម និងវប្បធម៌របស់ជនជាតិដើម។*

***អនុសញ្ញាស្តីពីសិទ្ធិកុមារ (១៩៨៩)***

*ទទួលស្គាល់តម្រូវការពិសេសរបស់កុមារពិការ ជំនួយ .......... នឹងត្រូវបានគេរៀបចំដើម្បីធានាថា កុមារពិការ មានឱកាសចូលរៀនដោយស្រួលបួល ...*

*នៅក្នុងរដ្ឋដែលជនជាតិភាគតិចដោយសារភាសា ឬសាសនា នៅមានកុមារដែលស្ថិតនៅក្នុងក្រុមនេះ នឹង មិនត្រូវបានគេបដិសេធន៍សិទ្ធិក្នុងការរីករាយ នឹងវប្បធម៌ សាសនា និងភាសានៅក្នុងសហគមន៍នោះទេ។*

# ៥. ធ្វើឱ្យការអប់រំអាចទទួលយកបាន

គេតែងសង្កេតឃើញមានការយកចិត្តទុកដាក់មិនបានជិតដល់លើវិស័យអប់រំពីជំនាន់មួយទៅជំនាន់មួយទៀត ហើយការធ្វើបែបនេះគឺជាការបង្កឲ្យភាពក្រីក្រចេះតែបន្តឥតឈប់។ បាតុភូតបែបនេះត្រូវបានចងក្រងជាឯកសារយ៉ាងច្រើនសំបូរបែប។ គេក៏បានដឹងច្បាស់គ្រប់ៗគ្នាដែរថា វ័យដំបូងនៃកុមារភាពគឺជាដំណាក់កាលយ៉ាងសំខាន់នៃការអភិវឌ្ឍន៍បញ្ញា ស្មារតីក្នុងការរៀនសូត្រ។ ក្របខ័ណ្ឌសកម្មភាពក្រុងដាកាផ្ដល់អាទិភាពសំរាប់អភិវឌ្ឍសក្ដានុភាពនៃសមត្ថភាពរបស់កុមារទាំងអស់ក្នុងការសិក្សាដោយកំណត់គោលដៅដើម្បីសំរេចការអប់រំសំរាប់ទាំងអស់គ្នាឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

## ៥.១. វិភាគអំពីដំណើរការការរៀន និងបង្រៀនទាំងស្រុង

លទ្ធផលដែលបានគិតទុកមុននៃដំណើរការរៀនសូត្រហាក់ដូចជាច្រើនតែឆ្លុះបញ្ចាំងអំពីការកំណត់និយមន័យគុណភាពដែលត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ។ បើនិយាយតាមការអប់រំដោយផ្អែកលើសិទ្ធិមនុស្ស សំរាប់ខ្នាតគំរូសិទ្ធិមនុស្សនេះ ក្រមខ័ណ្ឌសកម្មភាពរួមដែលមាន *ធនធាន–ដំណើរការ–លទ្ធផល* ចាំបាច់ត្រូវបន្ថែម *ការចុះឈ្មោះ និងលទ្ធផលរំពឹងសំរេចបានក្នុងរយៈពេលយូរអង្វែងថែមទៀត*។ នៅពេលនោះក្របខ័ណ្ឌនោះនឹងក្លាយទៅជា *ការចុះឈ្មោះចូលរៀន–ការដាក់ធនធាន–ដំណើរការបង្រៀន–លទ្ធផល–លទ្ធផលរំពឹងសំរេចបានក្នុងរយៈពេលយូរអង្វែង*។ ប៉ុន្តែគេត្រូវកត់សំគាល់ថា សន្ធិសញ្ញាអន្តរជាតិស្ដីពីសិទ្ធិមនុស្សមិនបានកំណត់និយមន័យនៃគុណភាពអប់រំទេ។ នេះគឺជាបញ្ហាដែលបន្សល់ទុកសំរាប់អ្នកអប់រំ និងចំណុចដាក់លាក់ពិស្ដារមានបញ្ជាក់នៅក្នុងច្បាប់អប់រំក្នុងប្រទេសនីមួយៗ។ ច្បាប់សិទ្ធិមនុស្សអន្តរជាតិកំណត់តួនាទីដែលការអប់រំត្រូវបំពេញ (ដូចជាការលុបបំបាត់ការរើសអើង ដូចមានបញ្ជាក់នៅក្នុងតារាងលេខ៩) និងគោលដៅដែលការអប់រំត្រូវសំរេចឲ្យបាន (មើលតារាងលេខ ២)។

សូចនាករណ៍ត្រូវបានបង្កើតឡើងដើម្បីតាមដានការអប់រំដោយផ្អែកលើទស្សនៈសិទ្ធិមនុស្ស និងចៀសមិនផុតទេថា ប្រទេសនីមួយៗស្ថិតក្នុងដំណាក់កាលនៃការរីកចំរើនខុសៗគ្នា។ ភាពខុសគ្នានៅក្នុងប្រទេស និងរវាងប្រទេសបង្ហាញពីកង្វះខាតសាលាដែលមានសុវត្ថិភាព និងបរិស្ថានល្អ និងខ្វះគ្រូដែលមានការបណ្ដុះបណ្ដាលគរុកោសល្យត្រឹមត្រូវ។

ភារកិច្ចរបស់រដ្ឋាភិបាលដើម្បីកំណត់ និងពង្រឹងស្តង់ដាអប់រំទាមទារឲ្យមានការវាយតម្លៃស្ថានភាពអប់រំបច្ចុប្បន្នឲ្យបានត្រឹមត្រូវតាមបរិការទិសដៅអន្តរជាតិ។ ស្តង់ដាដែលត្រូវបង្កើតត្រូវអនុវត្តឲ្យបានដូចគ្នានៅគ្រប់កន្លែង។ ស្ថាប័ន និងនីតិវិធីត្រូវតែកំណត់ឲ្យបានច្បាស់លាស់សំរាប់អនុវត្ត តាមដាន និងពង្រឹងស្តង់ដាទាំងនេះ។ ជាការពិតណាស់ គ្មានប្រព័ន្ធអប់រំណាដែលអាចអភិវឌ្ឍសក្ដានុភាពរបស់កុមារឲ្យបានពេញលេញនោះទេ ប្រសិនជាប្រព័ន្ធអប់រំនោះពុំមានឧបករណ៍គ្រប់គ្រាន់ បរិស្ថានពុំមានសុវត្ថិភាព ហើយគ្រូពុំមានការបណ្ដុះបណ្ដាលត្រឹមត្រូវ។ ប្រហែលគ្នានេះដែរ ការលុបបំបាត់ចោលការរើសអើងមិនអាចសំរេចបានតាមរយៈការអប់រំបានទេ ប្រសិនជាកុមារជនជាតិភាគតិច និងជនជាតិដើមបានចូលរៀនតែនៅក្នុងសាលាដែលពុំមានគុណភាព។

ចំណាប់អារម្មណ៍នៃសិទ្ធិមនុស្សក្នុងវិស័យអប់រំស្ថិតនៅលើអ្នករៀនសូត្រ ជាពិសេសកុមារ ហើយចំណុចសំខាន់នៃវិធីនេះគឺនិរន្តរភាព។ ការងារនេះបានសំរេចរួចហើយ ដូចដែលបានបញ្ជាក់ពីខាងដើមដោយការ កំណត់សិទ្ធិនៃការទទួលបានរបស់កុមារដូចដែលបានកំណត់ក្នុងកាតព្វកិច្ចរបស់រដ្ឋាភិបាល។ គម្រោងនីមួយៗរបស់អ្នកផ្ដល់ជំនួយអន្តរជាតិ ឬអង្គការក្រៅរដ្ឋាភិបាលអាចមានសារប្រយោជន៍សំរាប់ក្រុមកុមារណាមួយ ក៏ប៉ុន្តែផលប្រយោជន៍ដ៏ធំធេងរបស់អង្គការនេះត្រូវបាត់បង់ទៅវិញបន្ទាប់ពីគម្រោងរបស់គេបញ្ចប់។